# សេចក្ដីប្រកាសសម្រាប់
# រាស្ត្រអ៊ីស្រាអែល

### យេរេមា ៣១: ១០ខ

ព្រះដែលបានកំចាត់កំចាយសាសន៍អ៊ីស្រាអែលទៅ
ទ្រង់នឹងប្រមូលគេមកវិញ ហើយនឹងរក្សាគេ ដូចជាអ្នកគង្វាល
ឃ្វាលហ្វូងចៀមរបស់ខ្លួន ។ (១)

### ទំនុកតំកើង១២៩: ៥-៦

សូមឲ្យអស់អ្នកដែលស្អប់ក្រុងស៊ីយ៉ូន បានត្រូវខ្មាសហើយ
ត្រឡប់ថយក្រោយទៅ ៦ សូមឲ្យគេបានដូចជាស្មៅដែលដុះនៅលើ
ដំបូលផ្ទះដែលស្វិតក្រៀមទៅ មុនដែលដុះធំឡើងផង។

### ទំនុកតំកើង៥៥: ៩ក

ឱព្រះអម្ចាស់អើយសូមបំផ្លាញគំនិតគេឲ្យគេនិយាយសុទ្ធតែខុសគ្នា។

### ទំនុកតំកើង១២៥: ៣ក

ពីព្រោះដំបងនៃសេចក្ដីអាក្រក់នឹងមិនគ្របលើចំណែកនៃ
មនុស្សសុចរិតឡើយ។

### ១សាំយូអែល ១២: ២២

ដ្បិតព្រះយេហូវ៉ាទ្រង់មិនបោះបង់ចោលរាស្ត្រទ្រង់ឡើយ
ដោយព្រោះទ្រង់យល់ដល់ព្រះនាមទ្រង់ដ៏ជាធំ ពីព្រោះព្រះយេហូវ៉ាបានសព្វ
ព្រះហឫទ័យ និងយកអ្នករាល់គ្នា ធ្វើជារាស្ត្ររបស់ទ្រង់ ។

### ទំនុកតំកើង ៣៣: ៨-១២

ចូរឲ្យគ្រប់ផែនដីខ្លាចចំពោះព្រះយេហូវ៉ាហើយឲ្យគ្រប់មនុស្ស
នៅលោកីយ៍កោតក្រែងដល់ទ្រង់ចុះ ៩ ដ្បិតទ្រង់គ្រាន់តែមានព្រះបន្ទូល
នោះក៏កើតមានដូច្នោះទ្រង់បានបង្គាប់ នោះក៏មាននៅ ១០ ព្រះយេហូវ៉ាទ្រង់
ធ្វើឲ្យសេចក្ដីប្រឹក្សានៃអស់ទាំងនគរបានថ្លស់ការ ទ្រង់ធ្វើឲ្យគំនិតនៃជន
ទាំងឡាយបានទៅជាឥតការ ១១ ឯដំបូន្មានផងព្រះយេហូវ៉ាវិញ នោះជាប់
ជានិច្ចហើយដំរិះក្នុងព្រះហឫទ័យទ្រង់ក៏នៅជាដរាបដល់អស់ទាំងដំណត
ទៅ ១២ មានពរហើយ នគរណាដែលយកព្រះយេហូវ៉ាទុកជាព្រះរបស់ខ្លួនគឺ
សាសន៍ដែលទ្រង់បានរើស ទុកជាមរដករបស់ទ្រង់។

### ទំនុកតំកើង ១៧: ៧-៩

ឱព្រះដ៏ជួយសង្គ្រោះដោយព្រះហស្តស្តាំចំពោះអស់អ្នកដែល
ពឹងទ្រង់ ឲ្យគេបានរួចពីអ្នកតតាំងអើយសូមទ្រង់សំដែងសេចក្ដី
សប្បុរសដ៏ប្រាកដច្បាស់មកផង ៨ សូមការពាររក្សា សាសន៍អ៊ីស្រា
អែលដូចជាប្រស្រីភ្នែក សូមបាំងសាសន៍អ៊ីស្រាអែលនៅក្រោមម្លប់
ចំអេងស្លាបរបស់ទ្រង់ ៩ ឲ្យសាសន៍អ៊ីស្រាអែលបានរួចពីមនុស្ស
អាក្រក់ ដែលសង្កត់សង្កិនសាសន៍អ៊ីស្រាអែល ជាពួកសត្រូវយ៉ាង
សាហាវ ដែលឡោមព័ទ្ធ សាសន៍អ៊ីស្រាអែលជុំវិញ។

### ទំនុកតំកើង ១២៤

បើមិនមែនជាព្រះយេហូវ៉ា ដែលកាន់ខាងសាសន៍អ៊ីស្រា
អែល នោះគួរឲ្យអ៊ីស្រាអែលនិយាយឥឡូវថា ២ បើមិន មែនជាព្រះ
យេហូវ៉ាដែលកាន់ខាងសាសន៍អ៊ីស្រាអែលទេ ក្នុងកាលដែលមនុស្ស
បានលើកគ្នាទាស់នឹងសាសន៍អ៊ីស្រាអែល ៣ នោះប្រាកដជាគេបាន
លេបសាសន៍អ៊ីស្រាអែលទាំងអស់ហើយ គឺក្នុងកាលដែលសេចក្ដី
ក្រោធរបស់គេបានក្តៅឡើងទាស់ នឹងសាសន៍អ៊ីស្រាអែល ៤ យ៉ាង
នោះ ប្រាកដជាទឹកជំនន់បានលិចសាសន៍អ៊ីស្រាអែល គឺទឹកជ្រោះ
បានហូរមកគ្របលើព្រលឹងសាសន៍អ៊ីស្រាអែលហើយ ៥ អើ ទឹកវល់
ច្របល់បានហូរមកគ្របលើព្រលឹងសាសន៍អ៊ីស្រាអែល ៦ សូមឲ្យព្រះ
យេហូវ៉ាបានប្រកបដោយព្រះពរ ដែលទ្រង់មិនបានប្រគល់សាសន៍
អ៊ីស្រាអែល ឲ្យជារំពាដល់ធ្មេញគេ ៧ ព្រលឹងសាសន៍អ៊ីស្រាអែលបាន
រួចដូចជាសត្វស្លាបដែលហើររួចពីអន្ទាក់របស់នាយព្រានអន្ទាក់គេបាន
ដាច់ ហើយសាសន៍អ៊ីស្រាអែលបានរួចចេញ ៨ ឯសេចក្ដីជំនួយរបស់
សាសន៍អ៊ីស្រាអែល គឺដោយពឹងដល់ព្រះនាមព្រះយេហូវ៉ាដែលទ្រង់
បានបង្កើតផ្ទៃមេឃ និងផែនដី។

(១) *វត្តមាននៃភាពតានតឹងនេះវាត្រូវបានផ្លាស់ប្តូរ ពីព្រោះវាកំពុងតែកើតឡើងនៅពេលឥឡូវនេះ។*

(២) *ត្រូវបានផ្លាស់ប្តូរទៅរកជនជាតិអ៊ីស្រាអែល*


បកប្រែដោយ: ONE- 2- ONE CAMBODIA

អាស័យដ្ឋាន: # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦

សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

www.One-2-One world.org

www.derekprince.co.nz PC05